ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚៚✻៛៛

កងយោធពលខេមរភូមិន្ទ

អគ្គបញ្ជាការ

លេខ...២៥៤.ស.ស.៤

## សេចក្ដីសំរេច

## ស្ដីពីការបង្កើតផ្លាកសញ្ញារបស់ស្ថាប័នអភិវឌ្ឍន៍

## កងយោធពលខេមរភូមិន្ទ

---

### អគ្គមេបញ្ជាការ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីការ កែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ : ០៧/អនក្រ.បក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ : ៨៦ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០១ ស្ដីពីការកែសំរួលបង្កើត ផ្លាកសញ្ញាមួយចំនួនបំពេញបន្ថែមលើមាត្រា ៦ នៃអនុក្រឹត្យលេខ : ០៧/អនក្រ.បក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ ឯកសណ្ឋាន ផ្លាកសញ្ញា និងទង់ជ័យ នៃកង-យោធពលខេមរភូមិន្ទ
- តាមសំណើរបស់ទីចាត់ការអភិវឌ្ឍន៍ ។

### <u>សំរេច</u>

**<u>ប្រការ១</u>:** ត្រូវបានបង្កើតផ្លាកសញ្ញារបស់ស្ថាប័នអភិវឌ្ឍន៍កងយោធពលខេមរភូមិន្ទ បំពេញបន្ថែមលើមាត្រា៦ នៃអនុក្រឹត្យលេខ: ០៧/អនក្រ.បក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧ ។

**<u>ប្រការ២</u>:** អំពីរូបភាព ខ្នាត និង របៀបប្រើប្រាស់ :

ក- <u>រូបភាពនិងខ្នាត</u> :

មានរាងជារង្វង់មូលដែលមានអង្កត់ផ្ចិត ៦៨ម.ម ។ នៅជុំវិញមានលំអដោយក្បាច់ត្របកផ្កាអង្គរ អមកួរស្រូវរាងកោងស្នែងក្របី តំណាងអោយកំលាំងផលិតនិងភោគផលរបស់ផលិតកម្ម ។ នៅពីក្រោមមានចារឹកអក្សរ **អភិវឌ្ឍន៍ ខ.ភ.ម** ក្នុងផ្ទៃពណ៌ខៀវ និង ពណ៌ក្រហម មានកំពស់២ម.ម ។ ផ្ទៃខាងក្នុងខ័ណ្ឌដោយគំនូសរង្វង់ពីរជាន់ពណ៌ក្រហម មានអង្កត់ផ្ចិត៥០មម ហើយចែកចេញជាពីរផ្នែកត្រង់អង្កត់ផ្ចិត ។ ផ្នែកខាងលើមានពណ៌ផ្ទៃមេឃ និងមានដើមឈើដុះជាជួរ

ចំនួន៥ដើម ស្លឹកពណ៌បៃតង ដើមកណ្តាលខ្ពស់មានចុងប៉ះនឹងខ្សែរង្វង់ ហើយនិងពីរដើមអមសង្ខាង ដែលមានចុងទាបស្មើគ្នា ផ្នែកខាងក្រោមមានសំណង់ធារាសាស្ត្រទ្វារទឹកចំនួន៣ និង វាលស្រែពណ៌បៃតងអមប្រឡាយទឹក តំណាងអោយសម្បត្តិធនធានធម្មជាតិនិងការអភិវឌ្ឍន៍របស់ប្រទេសជាតិ ។

ខ- **របៀបប្រើប្រាស់ :**

ផ្លាកសញ្ញានេះត្រូវប៉ាក់ ឬ បោះពុម្ពនៅលើក្រណាត់ សំរាប់ពាក់នៅដៃអាវខាងឆ្វេង ចុះពីថ្នេរស្មា ៦ស.ម នៃឯកសណ្ឋាន ។ ផ្លាកសញ្ញានេះ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ចំពោះ នាយទាហាន នាយទាហានរងនិងពលទាហាន ក្នុងស្ថាប័នអភិវឌ្ឍន៍កងយោធពលខេមរភូមិន្ទ រួមមាន :

- ទីចាត់ការអភិវឌ្ឍន៍ អគ្គបញ្ជាការ
- ការិយាល័យអភិវឌ្ឍន៍ បណ្តាប្រភេទទ័ព
- ការិយាល័យអភិវឌ្ឍន៍ បណ្តាយោធភូមិភាគ
- ការិយាល័យអភិវឌ្ឍន៍ បណ្តាតំបន់ប្រតិបត្តិការសឹករងខេត្ត-ក្រុងនិងកងពល
- កសិដ្ឋាននិងតំបន់អភិវឌ្ឍន៍បណ្តាថ្នាក់ ។

**ប្រការ៣ :** ខុទ្ទកាល័យ អគ្គបញ្ជាការ ទីចាត់ការហិរញ្ញវត្ថុ ទីចាត់ការអភិវឌ្ឍន៍ និង ស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តន៍ សេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៤ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកញ្ញា ឆ្នាំ ២០០៤

អគ្គមេបញ្ជាការ

**នាយឧត្តមសេនីយ៍.កេ.គឹមយ៉ាន**

**កន្លែងទទួល**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការពារជាតិ
- អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ
  " ដើម្បីជូនជ្រាប"
- ដូចប្រការ ៣ " ដើម្បីមុខការ "
- ឯកសារ - កាលប្បវត្តិ

# គំរូសញ្ញាសំគាល់
# អភិវឌ្ឍន៍កងយោធពលខេមរភូមិន្ទ




